CITY OF
LONGBEACH

# សេចក្ដីប្រកាសពត៌មាន

សាលាក្រុងឡុងប៊ីឆ
ការិយាល័យពត៌មានសាធារណៈ
411 W. Ocean Blvd,
Long Beach, CA 90802

---

**4/3/2020**

សំរាប់ផ្សព្វផ្សាយបន្ទាន់ សេចក្ដីប្រកាសពត៌មាន# 040320

**ប្រធានបទ:** **សាលាក្រុងឡុងប៊ីឆទទួលនូវការផ្ដល់ជូនយ៉ាងច្រើនក្រៃលែង ក្នុងការបរិច្ចាគដើម្បីជាជំនួយ នៃការឆ្លើយតបទៅនិងជំងឺ COVID-19**
ទំនិញ, សេវានានា និងពេលវេលាស្ម័គ្រចិត្ត និងត្រូវផ្ដល់អោយតាមរយៈទំរង់អនឡាយ

**ទំនាក់ទំនង:** មជ្ឈមណ្ឌលពត៌មានរួម សាលាក្រុងឡុងប៊ីឆ
562.570.NEWS
jic@longbeach.gov

ក្រុងឡុងប៊ីឆ, រដ្ឋកាលីហ្វ័រញ៉ា - ថ្ងៃនេះ ក្រុងឡុងប៊ីឆធ្វើសេចក្ដីប្រកាសនូវជំហ៊ានបន្ថែមទៀត ដើម្បីសំរបសំរួលនៃការច្រើនលើសលុបនូវជំនួយសហគមន៍ និងអាជីវកម្ម ដែលសាលាក្រុងបានទទួល ក្នុងការជួយចាត់ចែងឆ្លើយតបទៅនិងជំងឺ COVID-19។

អភិបាលក្រុង Robert Garcia មានប្រសាសន៍ថា “ខ្ញុំមានការលើកទឹកចិត្តជាខ្លាំង ចំពោះបុគ្គល និងអាជីវកម្មជាច្រើនដែលបានទំនាក់ទំនងរូបខ្ញុំ និងបានផ្ដល់នូវការជួយ និងជំនួយរបស់ពួកគេ ក្នុងកំឡុងពេលដ៏លំបាកនេះ,”។ “អំណោយទាំងឡាយដែលបានទទួល និងផ្ដល់ជាធនធាននានាដ៏មានតំលៃ សំរាប់កិច្ចប្រឹងប្រែងជាបន្តរបស់ពួកយើង ដើម្បីប្រយុទ្ធប្រឆាំងនិងជំងឺ COVID-19។ វត្ថុសំខាន់មួយជាងគេបំផុត ក្នុងចំណោមវត្ថុសំខាន់ទាំងអស់ដែលយើងអាចធ្វើឥឡូវនេះ គឺជាការជួយគាំទ្រ និងថែរក្សាគ្នា ទៅវិញទៅមក”។

ក្នុងខណៈពេលដែលការធ្វើអន្តរៈសកម្ម ឬទំនាក់ទំនងតាមរយៈមនុស្សផ្ទាល់នៅមានកំរឹតនៅឡើយ ដោយបទបញ្ជាសុខាភិបាល, បញ្ជីខាងក្រោម គឺជាមធ្យោបាយបន្ថែមមួយចំនួន ដែលមនុស្សមានចំណាប់អារម្មណ៍អាចជួយមិត្តប្រជាពលរដ្ឋក្រុងឡុងប៊ីឆទាំងឡាយ របស់ពួកគេបាន:

- ជា អ្នកជិតខាងល្អ។ ក្នុងភាពជាដៃគូរជាមួយ យើងស្រឡាញ់ឡុងប៊ីឆ, សាលាក្រុងភ្ជាប់សមាជិកសហគមន៍នានាណា ដែលត្រូវការជំនួយ ជាមួយនិងអ្នកដែលមានបំណង និងចង់ជួយ។  ដោយបំពេញនូវ កាតអ្នកជិតខាង ទៅអ្នកជិតខាង (ផងដែរ មានជាភាសា Spanish, Tagalog និង ភាសាខ្មែរ Khmer), សមាជិកសហគមន៍ទាំងឡាយ អាចចែករំលែកនូវពត៌មានទំនាក់ទំនង និងប្រភេទនៃជំនួយ ដែលពួកគេអាចផ្ដល់អោយទៅកាន់

អ្នកជិតខាងនានា ដែលនៅជិត។ កាតដែលបានបោះពុម្ពទុកមុន អាចរកបានតាមរយៈការិយាល័យចៅសង្កាត់ ឬអាចស្នើសុំបាន ទីនេះ។

- បរិច្ចាគទៅកាន់ Long Beach Coronavirus Relief Fund ឬ មូលនិធិសង្គ្រោះខូរ៉ូណាវីរ៉ុសឡុងប៊ីឆ, ដែលនិងជួយដល់អង្គការដែលមានមូលដ្ឋាននៅសហគមន៍នានា ដែលនៅឯជួរមុខនៃការឆ្លើយតបជំងឺខូរ៉ូណាវីរ៉ុស ក្នុងក្រុងឡុងប៊ីឆ។
- បរិច្ចាគឈាម ប្រសិនបើអ្នកមានសុខភាពល្អ ហើយមានលក្ខណៈសម្បត្តិ ក្នុងការធ្វើអោយប្រាកដថា មានឈាមសំរាប់សង្គ្រោះជីវិតគ្រប់គ្រាន់នៅលើធ្មើ សំរាប់អ្នកដែលត្រូវការវាបំផុត។

ដើម្បីចាត់ចែង និងគ្រប់គ្រងនូវអំណោយ និងការផ្តល់នូវជំនួយទៅកាន់សាលាក្រុងឡុងប៊ីឆ, សាលាក្រុងបានអភិវឌ្ឍន៍នូវ ទំរង់ អនឡាញមួយ ដែលអាចនិងបញ្ចប់ដោយអាជីវកម្មមូលដ្ឋាន និងអ្នកស្ម័គ្រចិត្តសហគមន៍ ក្នុងការប្រមូលនូវពត៌មានពិស្តារអំពីទំនិញ និងសេវាកម្មនានា ដែលនិងត្រូវផ្តល់អោយ។ ពត៌មានដែលផ្តល់អោយទាំងឡាយ និងត្រូវការពារដោយអេឡិចត្រូនិចអំពីភាពឯកជន និងយកទៅពិនិត្យដើម្បីធ្វើការកំណត់នូវភាពស៊ីសង្វាក់គ្នាដ៏ប្រសើរបំផុត ជាមួយនិងតំរូវការប្រតិបត្តិស៊ីធី។ សមាជិកអំណោយរបស់ស៊ីធី និងក្រុមគ្រប់គ្រងអ្នកស្ម័គ្រចិត្ត និងធ្វើការទំនាក់ទំនងជាមួយបុគ្គល និងអាជីវកម្មទាំងឡាយ សំរាប់ការពិភាក្សា និងសំរបសំរួលជាបន្តរទៀត។

ទំរង់ថ្មី និងជួយសាលាក្រុងក្នុងការរៀបចំនូវអំណោយច្រើនមុខច្រើនបែបដែលបានទទួល ដូចជាការប្រើប្រាស់ទីកន្លែងអាជីវកម្ម ការដឹកជញ្ជូន និងសេវាកម្មចែកចាយ និងសំភារៈការពារផ្ទាល់ខ្លួន។ លើសពីនេះទៀត អំណោយជាអាហារ និងសំភារៈអនាម័យផ្ទាល់ខ្លួន សំរាប់ជនដែលជួបប្រទះនូវភាពគ្មានផ្ទះសំបែង និងការផ្តល់សេវាកម្មជាអ្នកស្ម័គ្រចិត្ត នៃវិស័យជំនាញខុសៗគ្នាច្រើនមុខ មានដាក់នៅក្នុងទំរង់ ផងដែរ។

វាបានត្រូវប្រមើលឃើញថា តំរូវការនានារបស់ស៊ីធីនិងផ្លាស់ប្តូរគ្រប់ពេល អាស្រ័យលើការអភិវឌ្ឍន៍នូវស្ថានភាពសុខភាព និងអ្វីដែលមិនមែនជាអាទិភាពបន្ទាន់ឥឡូវនេះ អាចនិងក្លាយជាតំរូវការសំខាន់បំផុត នាពេលអនាគត។ ពត៌មានស្តីអំពីអំណោយ ដែលមិនស៊ីសង្វាក់និងតំរូវការបច្ចុប្បន្នរបស់ស៊ីធី និងត្រូវរក្សាទុកជាឯកសារ សំរាប់ធ្វើការពិចារណានាពេលអនាគត។ ស៊ីធីនិងប្រើប្រាស់នូវធនធាន និងសេវាកម្មនានា ដែលបំពេញដ៏ប្រសើរ នូវការខ្វះចន្លោះនាពេលបច្ចុប្បន្នទាំងឡាយ ដើម្បីអោយទំនិញសេវាកម្មទាំងឡាយដែលនៅសល់ និងអ្នកស្ម័គ្រចិត្តអាចនិងត្រូវប្តូរទិសដៅ ទៅកាន់អង្គការដទៃទៀត នៅក្នុងសហគមន៍របស់យើង ដែលមានតំរូវការបន្ទាន់។

សំរាប់ពត៌មានថ្មីៗបំផុតស្តីអំពីជំងឺ COVID-19, ជាមួយនិងពត៌មានពិស្តារទាំងឡាយ ដែលសាលាក្រុងឡុងប៊ីឆកំពុងតែធ្វើ ដើម្បីរក្សានូវប្រជាពលរដ្ឋទាំងអស់របស់ខ្លួន អោយមានសុវត្ថិភាព, ទស្សនា www.longbeach.gov/COVID19 និងតាមមើល @LongBeachCity លើ Facebook, Twitter និង Instagram.

សំរាប់ពត៌មាន, រូបភាព, វីឌីអូ និងសេចក្តីប្រកាសនានាបន្ថែមទៀត នៃអ្វីដែលកំពុងកើតឡើងក្នុងក្រុងឡុងប៊ីឆ តាមមើលពួកយើង លើ Facebook, Twitter, Instagram និង YouTube.